*ភ្នំពេញ, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៣*

# សារាចរណែនាំលេខ ០០៦ សរ សកហវ

## ស្តីពីការបិទបញ្ជីចំណូល - ចំណាយថវិការដ្ឋចុងឆ្នាំ ១៩៩៣

ក្នុងឆ្នាំ ១៩៨៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិបានផ្សព្វផ្សាយសារាចរណែនាំលេខ ១២ ( សរណន ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៤ ណែនាំការបិទបញ្ជីចំណូល - ចំណាយថវិការដ្ឋឆ្នាំ ១៩៨៤ ។

ចំពោះឆ្នាំ ១៩៩៣ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំឡើងវិញ នូវកិច្ចបិទ បញ្ជីចំណូល - ចំណាយថវិការដ្ឋចុងឆ្នាំ ១៩៩៣ ដើម្បីបង្កើនការងារត្រួតពិនិត្យដាស់តឿនជំរុញការងារបង់ចំណូលនាចុងឆ្នាំ និង បង្កើនការងារគ្រប់គ្រងចំណាយថវិកាទប់ទល់នឹងស្ថានភាពខំប្រឹងបញ្ចេញទុនអោយអស់ ចាយវាយខុសលក្ខការណ៍របប និងរាំងស្កាត់បាតុភាពឆ្លៀតចំណាយអោយអស់នូវគំរោងថវិកាដែលបាន ផ្តល់អោយ ។

ការងារទាំងនេះជាការងារមួយចាំបាច់បំផុតរបស់គ្រប់ ស្ថាប័នក្រសួង ខេត្ត ក្រុង និងគ្រប់សហគ្រាសដែលទទួលទារត្រូវតែខិតខំអនុវត្តយ៉ាងតឹងរឹងដាច់ខាត ។ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ សង្កត់ធ្ងន់លើខ្លឹមសារមួយចំនួនដូចតទៅ :

១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្អាកការផ្តល់និងរតនាគារ ធនាគារផ្អាកការផ្ទេរថវិកាដូច ខាងក្រោមនេះ:

- ចាប់ពីម៉ោង ១៤ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៩៣ ចំពោះខេត្ត ស្ទឹងត្រែង ព្រះវិហារ រតនគិរី មណ្ឌលគិរី និងបណ្តា អង្គភាពក្រោមចំណុះក្រសួងនានា ដែលបោះទីតាំងធ្វើសកម្មភាពលើភូមិសាស្ត្រ នៃខេត្តទាំងនោះ ។
- ចាប់ពីម៉ោង ១៤ ថ្ងៃទី ២០ ខែ ១២ ឆ្នាំ ១៩៩៣ ចំពោះ ខេត្តបាត់ដំបង បន្ទាយមានជ័យ ពោធិសាត់ កំពង់ឆ្នាំង កំពង់ធំ សៀមរាប និងអង្គភាពចំណុះក្រសួងនានាដែលបោះទីតាំងធ្វើ សកម្មភាពលើភូមិសាស្ត្រនៃខេត្តទាំងនោះ ។
- ចាប់ពីម៉ោង ១៤ ថ្ងៃទី ២៥ ខែ ១២ ឆ្នាំ ១៩៩៣ ចំពោះខេត្ត ស្វាយរៀង កណ្តាល ព្រៃវែង កំពង់ចាម កំពង់ស្ពឺ កំពត តាកែវ ក្រចេះ កោះកុង ក្រុងព្រះសីហនុ ក្រុងកែប និងក្រុងភ្នំពេញ និងក្រសួងអង្គភាពកណ្តាល ដែលបោះទីតាំងធ្វើសកម្មភាពលើភូមិសាស្ត្រខេត្ត ក្រុង ទាំងនោះ ។
- បណ្តាអង្គភាពចំណាយផ្ទាល់មិនបែងចែកជាថវិកាកណ្តាល ឬមូលដ្ឋានឡើយ ទាំងអស់ត្រូវផ្អាកចេញបញ្ជាផ្ទេរប្រាក់នៅម៉ោង ១៤ ថ្ងៃទី ២៧ ខែ ១២ ដើម្បីធានាអោយបញ្ជាផ្ទេរប្រាក់នេះ មានពេលវេលាគ្រប់គ្រាន់អនុវត្តបាននូវការចំណាយមុនថ្ងៃទី ៣១ ខែ ១២ ឆ្នាំ ១៩៩៣ ។ គ្រប់ការចំណាយដកសាច់ប្រាក់ចេញពីរតនាគារ និងធនាគារ របស់អង្គភាពចំណាយផ្ទាល់ត្រូវបានអនុវត្តរហូតដល់ថ្ងៃទី ៣១ ខែ ១២ ។

២ - អង្គភាពសេដ្ឋកិច្ចថ្នាក់កណ្តាល ឬមូលដ្ឋានដែលមានគណនីប្រាក់ផ្ញើនៅតាមធនាគារ រតនាគារជាបឋមត្រូវត្រួតពិនិត្យអោយបានហ្មត់ចត់ដោយខ្លួនឯង នូវប្រភពដើមនៃបណ្តាខ្ទង់ប្រាក់ផ្ញើទាំងនោះ ដើម្បី :

- បើមានចំនួនប្រាក់ ដែលត្រូវបង់ចំណូល ចូលថវិការដ្ឋ ហើយមិនបានបង់នោះ ត្រូវធ្វើលិខិតបង់ប្រាក់ កត់ត្រាអោយបានត្រឹមត្រូវតាមប្រភពខ្ទង់ប្រការជំពូកចំណូល ហើយបង់ជាបន្ទាន់បង់ទាំងអស់បញ្ចូលថវិកា មុនពេលធនាគារ រតនាគារបិទបញ្ជីឆ្នាំ ។

- ចំពោះខ្ទង់ប្រាក់ដែលត្រូវបានថវិការផ្តល់ ហើយមិនចំណាយ ឬក៏ចំណាយហើយតែនៅ សល់ក៏ត្រូវ ធ្វើលិខិតបង់ប្រាក់សងអោយថវិកាវិញ ដើម្បីបន្ថយការផ្តល់តាមប្រភេទខ្ទង់ប្រការជំពូកដែលបានផ្តល់ " សំណេះចំណាយ " ។

៣- ករណីពិសេសដែលត្រូវលើកលែង មិនបាច់បង្វែរចូលថវិកាវិញ នាថ្ងៃទី ៣១ ខែ ១២ ឆ្នាំ ១៩៩៣ ហើយត្រូវកត់ត្រាបន្តចំណាយចូលក្នុងឆ្នាំ ១៩៩៤ ដោយធ្វើកិច្ចបញ្ជីការ តំរូវទៅតាមតារាងរាយនាមមាតិកាថវិការដ្ឋថ្មី នូវប្រភពទុនដែលថវិការដ្ឋផ្តល់សំរាប់ចំណាយឆ្នាំ ១៩៩៣ តែដកពុំទាន់ រួមមាន :

- ចំណាយសំរាប់ក្រសួងការពារជាតិ

- ចំណាយសំរាប់ក្រសួងមហាផ្ទៃនិងសន្តិសុខ

- ចំណាយសំរាប់ទុនសាងសង់ " ជំពូក ៩ "

ក៏ប៉ុន្តែអង្គភាពទាំងនេះ ក៏ចាំបាច់ត្រូវធ្វើរបាយការណ៍បិទបញ្ជីចំណូល-ចំណាយឆ្នាំ ១៩៩៣ ផ្ញើជូនក្រសួង អាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចក្រសួងដទៃទៀតដែរ ។

៤- យ៉ាងយឺតបំផុតថ្ងៃទី ៣១ ខែ ១២ អង្គភាពទាំងឡាយត្រូវធ្វើតារាងប្រកាសចំពោះចំនួន ប្រាក់ដែល នៅសល់ ក្នុងបណ្តាគណនីដូចពោលខាងលើ វិភាគអោយបានច្បាស់លាស់ពីប្រភពដើម នៃខ្ទង់ប្រាក់នីមួយៗភ្ជាប់ នឹងសំណើវិនិច្ឆ័យ ចំពោះសមតុល្យទាំងនោះផ្ទុវផ្តង និងយកហត្ថលេខាដែលបញ្ជាក់ទទួលស្គាល់របស់រតនាគារ ធនាគារ ទីកន្លែងដែលបើកគណនីរួចហើយត្រូវរាយការណ៍ឡើងមកប្រធាន អង្គភាព ស្ថាប័នអាណាព្យាបាល និងស្ថាប័នហិរញ្ញវត្ថុ ។ អង្គភាពទាំងនោះរួបមាន :

- បណ្តាអង្គភាព រដ្ឋបាលនៃថ្នាក់កណ្តាល ដែលស្ថិតនៅរាជធានីភ្នំពេញ ត្រូវរាយការណ៍អោយប្រធាន អង្គភាព ក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- បណ្តាអង្គភាពរដ្ឋបាល ឬសហគ្រាសរបស់ចំណុះក្រសួងនានា សកម្មភាពលើភូមិសាស្ត្រ ខេត្ត ក្រុង ត្រូវ ធ្វើរបាយការណ៍អោយមន្ទីរហិរញ្ញវត្ថុ ខេត្ត ក្រុង ក្រសួងអាណាព្យាបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- បណ្តាអង្គភាពរដ្ឋបាលរបស់ខេត្ត ក្រុង ត្រូវរាយការណ៍អោយប្រធានអង្គភាព និងមន្ទីរហិរញ្ញវត្ថុ រួចហើយមន្ទីរហិរញ្ញវត្ថុ ត្រូវបូកសរុបរាយការណ៍មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៥- ស្ថាប័នហិរញ្ញវត្ថុទទួលបានរបាយការណ៍ ត្រូវពិនិត្យមើលថា បើអង្គភាពរដ្ឋបាលឬបណ្តាខេត្ត ក្រុង មានសល់សមតុល្យ ត្រូវវិភាគសមតុល្យនោះ តើសល់ពីអ្វីខ្លះ ជាទុនថវិការដ្ឋផ្តល់ ដកចំណាយពុំទាន់ ឬក៏ជាមុខសញ្ញាផ្សេងទៀតរួចហើយត្រូវជូនដំណឹងទៅរតនាគារ ឬធនាគារ កន្លែងដែលបណ្តាអង្គភាពឬខេត្ត ក្រុង ទាំងនោះបើកគណនី ដើម្បីបង្វែរសមតុល្យទាំងនោះចូលថវិការដ្ឋជាបន្ទាន់អាស្រ័យដោយឆ្នាំ ១៩៩៤ យើងត្រូវចាប់ផ្តើមអនុវត្តតារាងរាយនាមមាតិកាថវិការដ្ឋថ្មី ។ ការអនុវត្តរបៀបនេះជាការបង្កលក្ខណៈងាយស្រួលដល់កិច្ចបញ្ជិកា សំរាប់ឆ្នាំ ១៩៩៤ លើកលែងតែ

ថវិកាស្ថិតក្នុងករណីពិសេសដូចជំរាបជូនក្នុងចំណុច ៣ ខាងលើ តែការអនុវត្តបន្តចំណាយនេះ ត្រូវធ្វើកិច្ចបញ្ជីការ តាមតារាងមាតិកាថវិកាថ្មីដែរ ។

៦- ចំពោះទឹកប្រាក់ដែលជាថវិការដ្ឋផ្តល់ ហើយដកចំណាយពុំទាន់ សាប៊ីអង្គភាពនីមួយៗ ដល់ដើមឆ្នាំ ១៩៩៤ អាចរៀបចំសណ្ឋំឯកសារជាថ្មី ដោយភ្ជាប់បន្ថែមនូវប្រការបង់ចូលថវិការដ្ឋរបស់ រតនាគារ ឬធនាគារស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមបែបបទតារាងរាយនាមថវិការដ្ឋថ្មី ។

៧- នៅថ្ងៃទី ៣១ ខែ ១២ បើអង្គភាពណាមិនបង់ មិនធ្វើតារាងប្រកាសប្រាក់ចំណូលដែលត្រូវបង់ឬប្រាក់ថវិកាផ្តល់ហើយមិនចំណាយ ឬក៏ចំណាយចំមុខសញ្ញា ហើយមាននៅសល់រតនាគារ ធនាគារក្រោយពីពិនិត្យ ឃើញប្រាក់សល់នោះជាប្រាក់ ដូចជំរាបជូនខាងលើរួចហើយ ត្រូវម្ចាស់ការផ្ទេរជាស្វ័យប្រវត្តិ នូវចំនួនទឹកប្រាក់សល់ទាំងអស់របស់បណ្តាគណនីប្រាក់បញ្ញើ ដូចពោលខាងលើ ចូលខ្ទង់ " ចំណូលផ្សេងៗ " របស់ថវិការដ្ឋក្នុងឆ្នាំ ។

៨- បណ្តាអង្គភាពផលិតអាជីវកម្ម ម្ចាស់ការហិរញ្ញវត្ថុ ស្វ័យាភិបាលសេដ្ឋកិច្ច ដែលមានកាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ ហើយមិនទាន់បង់គ្រប់តាមផែនការ ត្រូវរួតរះបង់អោយបានមុន រតនាគា ធនាគារបិទបញ្ជី ។

៩- បណ្តាអង្គភាពរដ្ឋបាល រៀងរាល់ខែ ត្រូវអនុវត្តចាំបាច់របបផ្ទៀងផ្ទាត់ប្រៀបធៀបតួលេខជា មួយរតនាគារ កន្លែងដែលខ្លួនទាក់ទងអំពីចំណូលបង់ចូលថវិការដ្ឋ ចំនួនប្រាក់ថវិការដ្ឋផ្តល់ ចំនួនប្រាក់បង់បន្ថយការផ្តល់ ។ ចុងឆ្នាំសុទ្ធសឹងត្រូវធ្វើការផ្ទៀងផ្ទាត់សារឡើងវិញ ធានាចំនួនលេខចំណូល-ចំណាយ អោយបានត្រឹមត្រូវប្រាកដប្រជា ។

បណ្តាមន្ទីរហិរញ្ញវត្ថុត្រូវម្ចាស់ការជំរុញបណ្តាអង្គភាពនៅតាមមូលដ្ឋានអោយអនុវត្តរបបផ្ទៀងផ្ទាត់ប្រៀបធៀបតួលេខ ។ ក្រៅពីនេះនៅមានភារកិច្ចចាំបាច់ផ្ទៀងផ្ទាត់ប្រៀបធៀបតួលេខសរុបរបស់មូលដ្ឋាន ជាមួយរតនាគារខេត្ត ក្រុង ហើយចាំបាច់ត្រូវមានការបញ្ជាក់ទទួលស្គាល់របស់រតនាគារខេត្ត ក្រុងផង មន្ទីរហិរញ្ញវត្ថុ ត្រូវភ្ជាប់តារាងតួលេខផ្ទៀងផ្ទាត់នេះចូលក្នុងរបាយការណ៍សរុបសំរេចទូទាត់ចំណូល -ចំណាយថវិការដ្ឋប្រចាំឆ្នាំ ។

ដោយឆ្នាំ ១៩៩៤ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមតារាងរាយនាមថវិការដ្ឋ ដើម្បីតំរូវទៅតាមការវិវឌ្ឍន៍នៃខឿនសេដ្ឋកិច្ចជាតិ ដើម្បីរក្សាភាពងាយស្រួលក្នុងកិច្ចបញ្ជីការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំណូមពរអោយ ក្រសួងនិងខេត្ត ក្រុង អង្គភាពចំណុះក្រសួង បោះទីតាំងនៅមូលដ្ឋាន " អង្គភាពគ្រោងទូទាត់ " ត្រូវបង្វែរ សមតុល្យទាំងអស់បង់ចូលថវិការដ្ឋ លើកលែងតែករណីពិសេសដូចជំរាបជូនខាងលើ ។

ការបិទបញ្ជីចំណូល-ចំណាយថវិកាចុងឆ្នាំ គ្មានជះឥទ្ធិពលអសកម្មអ្វីដល់ការងារចំណូល-ចំណាយថវិកា ការងារបើកប្រាក់ បង់ប្រាក់ និងទំនាក់ទំនងរវាងរតនាគារ ធនាគារ ជាមួយបណ្តាអង្គភាពឡើយ ។ សកម្មភាពអនុវត្តថវិការបស់ឆ្នាំចាស់ ត្រូវបញ្ចប់នៅថ្ងៃទី ៣១ខែ ១២និងសកម្មភាពអនុវត្តថវិកាឆ្នាំថ្មីត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ។

**កំណត់ចំណាំ :**

ចំពោះមន្ទីរហិរញ្ញវត្ថុគ្រប់ខេត្ត ក្រុង និងបណ្តាអង្គភាពទាំងឡាយចំណុះក្រសួង ដែលបោះទីតាំងតាមបណ្តាខេត្ត ក្រុង ដើម្បីធានាបើកផ្តល់បៀវត្សខែ ១២ និងបង្កលក្ខណៈងាយស្រួលដល់កិច្ចបញ្ជីការបំណាច់ឆ្នាំ ១៩៩៣ ត្រូវរួត

មកទាក់ទងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជៀសវាងការយឺតយ៉ាវ ព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពុំរក្សា សមតុល្យ ទុកជូនបណ្ដាអង្គភាពទេ ។

ក្នុងរយៈកាលអនុវត្តបើមានជួបការលំបាក ស្ថាប័នក្រសួងដូចជាខេត្ត ក្រុង ត្រូវរាយការណ៍មកក្រសួង ហិរញ្ញវត្ថុ ដើម្បីពិនិត្យពិចារណាដោះស្រាយបានទាន់ពេលវេលា ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**សម រង្ស៊ី**

********